# របាយការណ៍ប្រចាំខែមករា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែមករា ឆ្នាំ ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣០នាក់ ស្រ្តី ០៤នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>**÷

- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៤ និងទិសដៅឆ្នាំ២០១៥ ថ្ងៃទី០៥/០១/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំពិភាក្សាដោះស្រាយស្ថានភាពខេត្ត ដើម្បីរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត (២០១៥-២០១៩) ថ្ងៃទី០៨/០១/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមក្នុងពិធីសម្ពោធអគារសិក្សានៅគរុកោសល្យខេត្ត ថ្ងៃទី ១៤/០១ /២០១៥
- ចូលរួមប្រជុំពិភាក្សាការងារលទ្ធកម្មឆ្នាំ២០១៥ នៅថ្ងៃទី០៩/០១/២០១៥
- ចូលរួមប្រជុំត្រៀមរៀបចំបុណ្យឆ្លងទន្លេ នៅថ្ងៃទី១៩/០១/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រកាសតែងតាំងប្រធានរតនាគារខេត្តថ្មី នៅថ្ងៃទី១៣/០១/២០១៥
- ចូលរួមវេទិកាសាធារណៈនៅស្រុកសំបូរ ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ ស្រុកស្នួល ស្រុកឆ្លូង និងក្រុងចេះ
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី៤ ឆ្នាំ២០១៤ របស់គណៈកម្មការនាយកមូលនិធិសមធមិ នៅមន្ទីរពេទ្យបង្អែកឆ្លូង ថ្ងៃទី២៦-២៧/០១/២០១៥ នៅមន្ទីរពេទ្យបង្អែកខេត្ត
- ចូលរួមសន្និបាតបូកសរុបការងារ ឆ្នាំ២០១៣-២០១៤ និងលើកទិសដៅឆ្នាំ២០១៥ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ថ្ងៃទី២៣/០១/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមកិច្ចប្រជុំសាមញ្ញរបស់ គកសក ក្រុមប្រឹក្សាខេត្ត ថ្ងៃទី២៣/០១/២០១៥ ។

3. **<u>សកម្មភាពតាមការិយាល័យ</u>**÷

3.1. **<u>ការិយាល័យរដ្ឋបាល និងបុគ្គលិក</u>**÷

ក. <u>ផ្នែកការងារលិខិតចូល</u> ÷ សរុបចំនួន ៥៧ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០៦លេខ
- លិខិតរបស់ក្រសួងសាម៉ី ចំនួន ០៨លេខ
- លិខិតក្រសួងនានា ចំនួន ១១ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៣២លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ១៣ លេខ ក្នុងនោះមាន

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ០៨ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ០៣ លេខ
- ស្ថាប័ននានា ចំនួន០២ លេខ

គ. ផ្នែកការងារលិខិតបញ្ជាបេសកកម្ម÷ សរុបចំនួន ២៤ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកម្មលោកប្រធានមន្ទីរពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន០២ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ២២ លេខ

ឃ. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានជាប្រចាំថ្ងៃ ។

3.2. **ការិយាល័យផ្លូវលំជនបទ÷**

- បានរៀបចំគម្រោង ដើម្បីសុំការអនុម័តសម្រាប់ ផែនការឆ្នាំ២០១៥ ៣គម្រោង
- ចុះសិក្សាផ្លូវជួសជុលភូមិខ្សាត់ទៅស្ទឹងទ្រ ប្រវែង ៦,៨០០ ម ស្ថិតនៅឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ដើម្បី ត្រៀមធ្វើការជួសជុល
- ចុះសិក្សាផ្លូវថែទាំជាលក្ខណៈខួប ភូមិសំរ៉ង ទៅ ភូមិចឹង ប្រវែង ៨ គ.ម ស្ថិតនៅឃុំឃ្សឹម និងភូមិក្បាលស្នួល ទៅ ភូមិស្នួលកើត ប្រវែង ៤ គ.ម ស្ថិតនៅឃុំស្នួល ស្រុកស្នួល
- ចុះសិក្សាផ្លូវថែទាំជាលក្ខណៈប្រចាំ ប្រវែង ២៩,៩០ គ.ម ស្ថិតនៅភូមិវាលកន្សែងភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង
- មន្ទីរបានចូលរួមជាមួយនាយកដ្ឋានផ្លូវលំជនបទចុះសិក្សាស្ពាននៅភូមិប្រម៉ា ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ ទៅភូមិកំពាន់ ឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ (តាមសំណូមពរវេទិការសាធារណៈនៅភូមិប្រម៉ា)
- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ក្នុងស្រុកស្នួល ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ និងផែនទីក្នុងខេត្ត បានចំនួន ៦ ខ្សែ ប្រវែង ១៩,២៨២ គ.ម ។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷**

- ចុះពិនិត្យអណ្តូងស្នប់ខូចនៅឃុំ០២ធ្នូ ស្រុកស្នួល
  - ភូមិជើងឃ្លូ មានអណ្តូងស្នប់ ០៤ អណ្តូង ខូច ០២ អណ្តូង
  - ភូមិជើងឃ្លេ មានអណ្តូងស្នប់ ០៧ អណ្តូង ខូច ០២ អណ្តូង
  - ភូមិច្រាប មានអណ្តូងស្នប់ ០៧ អណ្តូង ខូច ០២ អណ្តូង
  - ភូមិជើងប្រវ៉ាញ មានអណ្តូងស្នប់ ០៨ អណ្តូង ខូច ០២ អណ្តូង ។

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷**

3.5. **ការិយាល័យអភិវឌ្ឍន៍សហគមន៍÷**

- ចុះបណ្តុះបណ្តាល គ.អ.ភ ស្តីពី និរន្តរភាពនៃការអភិវឌ្ឍសហគមន៍ នៅស្រុកឆ្លូង ដោយមានការសហការរវាងមន្ទីរអភិវឌ្ឍន៍ជនបទ និងអង្គការឆាលហ្វានកម្ពុជាប្រចាំខេត្តក្រចេះ បានចំនួន ០៤ វគ្គ បន្ថែមទៀត ស្មើនឹង ០៤ ឃុំ (ឃុំហាន់ជ័យ ឃុំពង្រ ឃុំខ្សាច់អណ្តែត និងឃុំដីរីផុង) ស្មើនឹង ១៨ភូមិ និងមានអ្នកចូលរួម ១១៩ នាក់ ស្ត្រី ៥៩ នាក់
- រៀបចំផែនការសកម្មភាពឆមាសទី១ (ខែមករារហូតដល់ខែមិថុនា) សម្រាប់ឆ្នាំ២០១៥ ដើម្បីចុះត្រួតពិនិត្យតាមដានសមាសភាព និងសកម្មភាព គ.អ.ភ នៅក្នុងស្រុកស្នួល និងស្រុកសំបូរ
- ចុះសិក្សាពីតម្រូវការនានា ដើម្បីរៀបចំគម្រោងសន្តិសុខស្បៀង នៅភូមិចំនួន០៣ (បី) គឺភូមិថ្មល់ ភូមិវត្ត និងភូមិសំបូរសែនជ័យ នៃឃុំស្វាយជ្រះ ស្រុកស្នួល
- ចុះតាមដាន និងត្រួតពិនិត្យ សមាសភាព និងសកម្មភាព គ.អ.ភ នៅឃុំស្វាយជ្រះ ស្រុកស្នួល បានចំនួន០៨ភូមិ ។

3.6. **<u>ការិយាល័យជនជាតិដើមភាគតិច</u>÷** (គ្មានសកម្មភាព)

3.7. **<u>ការិយាល័យថែទាំសុខភាពជនបទ</u>÷**

- ប្រជុំផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យជនបទថ្នាក់ឃុំ ស្ថិតនៅឃុំកោះខ្ញែរ មានអ្នកចូលរួម ១១នាក់ ស្ត្រី២ នាក់
- ផ្សព្វផ្សាយ និងបំផុសប្រជាជនអោយយល់ដឹង អំពីអនាម័យ ហើយស្ម័គ្រចិត្តសាងសង់បង្គន់ដោយខ្លួនឯង ស្ថិតនៅឃុំកោះខ្ញែរ មានអ្នកចូលរួម ៩៥នាក់ ស្ត្រី៤៥ នាក់
- ប្រជុំផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យសហគមន៍ជនបទ អ្នកចូលរួម ១៥៧ នាក់ ស្ត្រី៨២ នាក់ ក្នុងឃុំខ្សាច់អណ្តែត ស្រុកឆ្លូង
- ចុះផ្សព្វផ្សាយ និងបំផុសប្រជាជនឲ្យយល់ដឹងអំពីអនាម័យ ហើយស្ម័គ្រចិត្តសាងសង់បង្គន់ ដោយខ្លួនឯង បានចំនួន ១១២ បង្គន់ ក្នុងស្រុកឆ្លូង
    - ឃុំកញ្ជរ ៥២ បង្គន់
    - ឃុំឆ្លូង ២១ បង្គន់
    - ឃុំព្រែកសាម៉ាន់ ៣៩ បង្គន់ ។

3.8. **<u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ</u>÷**

លោក ឈាង ស៊ីថា អនុប្រធានការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាល PSAM ចាប់ពីថ្ងៃទី ០៩-២១ ខែមករា ឆ្នាំ២០១៥ នៅខេត្តកំពង់ធំ ក្រោមការឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ ។

4. **<u>ទិសដៅបន្ត</u>÷**

- ចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ក្នុងស្រុកស្នួល ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ និងផែនទីក្នុងខេត្តក្រចេះ
- បន្តចុះពិនិត្យអណ្តូងស្នប់ដែលខូចនៅក្នុងស្រុកស្នួល

- ចុះតាមដាន និងត្រួតពិនិត្យការសាងសង់បង្គន់អនាម័យ ស្រុកឆ្លូង ស្រុកសំបូរ ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ
- បន្តចុះតាមដានសមាសភាព និងសកម្មភាពរបស់ គ.អ.ភ នៅក្នុងស្រុកស្នួលបន្តទៀត ។

**ប្រធានមន្ទីរ**